ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ: ១៩៩/១៤ ក.អ.ជ.ប្រក

ថ្ងៃ ពុធ ១០ រោច ខែ ស្រាពណ៍ ឆ្នាំមមី ព.ស. ២៥៥៨

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែសីហា គ.ស. ២០១៤

# ប្រកាស

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទក្រាលកៅស៊ូ និងបេតុង ក្នុងព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ចរាចរណ៍ផ្លូវគោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងប្រកាសលេខ ១៤២/១៤ ក.អ.ជ/ប្រ.ក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំដែលបើកបរលើបណ្តាញផ្លូវជនបទក្រាលកៅស៊ូ និងបេតុង ក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ១.-** តែងតាំងសមាសភាពគណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើស



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

ទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទក្រាលកៅស៊ូ និងបេតុង ក្នុងព្រះរាជាណាចក្រកម្ពុជា មានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម | **សួស គង់** | ជាប្រធាន |
| ២. | ឯកឧត្តម | **ចាន់ ដារ៉ុង** | ជាអនុប្រធាន |
| ៣. | លោក | **ទូច សំណាង** | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៤. | លោក | **ឡុង គីមហុង** | ជាសមាជិក |
| ៥. | លោក | **ធុន ចាន់ដារ៉ា** | ជាសមាជិក |
| ៦. | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត | | ជាសមាជិក |

**ប្រការ ២.-** គណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទក្រាលកៅស៊ូ និងបេតុង ក្នុងព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចដូចខាងក្រោម÷

- ធ្វើសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំអនុវត្តសំដៅទប់ស្កាត់សកម្មភាពយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់និងយានយន្តខុសទំហំលើផ្លូវជនបទ ដាក់ជូនក្រសួងពិនិត្យ និងសម្រេច
- រៀបចំ និងដាក់បញ្ចូលផែនការថវិការបស់គណៈកម្មាធិការសម្របសម្រួល និងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំលើបណ្តាញផ្លូវជនបទទៅក្នុងកញ្ចប់ថវិការបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- សម្របសម្រួល និងលើកកម្ពស់ការពិនិត្យតាមដានសកម្មភាពរបស់អង្គភាពត្រួតពិនិត្យទម្ងន់ និង ទំហំយានយន្តផ្ទុកលើសទម្ងន់កម្រិតកំណត់
- រៀបចំកាលវិភាគការងារសម្រាប់អង្គភាពត្រួតពិនិត្យទម្ងន់ និងទំហំយានយន្តលើផ្លូវជនបទ
- ធ្វើទំនាក់ទំនង និងសហការជាមួយស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់សកម្មភាពដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំ
- ធ្វើទំនាក់ទំនងជាមួយនគរបាលចរាចរណ៍រាជធានី ខេត្ត ដើម្បីជួយនៅតាមទីតាំងត្រួតពិនិត្យទម្ងន់ និងទំហំរបស់យានយន្ត
- រៀបចំបង្កើតបទបញ្ជាផ្ទៃក្នុងដើម្បីធានាការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព
- ធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងអភិវឌ្ឍន៍ជនបទ អំពីសកម្មភាពនៃការត្រួតពិនិត្យយានយន្តផ្ទុកលើសទម្ងន់កម្រិតកំណត់ និងយានយន្តខុសទំហំ
- អនុវត្តកិច្ចការផ្សេងទៀតដែលក្រសួងប្រគល់ជូន។

**ប្រការ ៣.-** សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤.-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ គ្រប់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងសាមីខ្លួនដូចមានក្នុងប្រការ ១ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជា សុផារ៉ា

__*កន្លែងទទួល*__

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងមហាផ្ទៃ*
*- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*-មន្ទីរពាក់ព័ន្ធ*
*"ដើម្បីជូនជ្រាប"*
*-ដូចប្រការ ១*
*"ដើម្បីអនុវត្ត"*
*-ឯកសារ - កាលប្បវត្តិ*